ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៣
សេចក្ដីប្រកាសព័ត៌មានបន្ទាន់

ទំនាក់ទំនងផ្នែកព័ត៌មាន៖
**លោកស្រី ភៀនផន ឌីតេស**, អ្នកសម្របសម្រួលយុទ្ធនាការប្រចាំប្រទេសថៃ, ទន្លេអន្តរជាតិ, ប្រទេសថៃ, អ៊ីម៉េល៖ Pai@internationalrivers.org, Tel: +66 814 220 111

**លោកស្រី ឡាំ ធីធូ ស៊ូ**, អ្នកសម្របសម្រួលបណ្ដាញទន្លេប្រចាំប្រទេសវៀតណាម និង ជាប្រធានមជ្ឈមណ្ឌលស្រាវជ្រាវសង្គមនិងអភិវឌ្ឍន៍, ប្រទេសវៀតណាម
អ៊ីម៉េល៖ csrd.hue@gmail.com, Tel: +84 945503508
**លោក ឈិត សំអាត**, នាយកប្រតិបត្តិ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា, ប្រទេសកម្ពុជា, អ៊ីម៉េល៖ samath@ngoforum.org.kh, Tel : +855 12 928 585

**លោក ទេព ប៊ុណ្ណារិទ្ធ** ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃអង្គការសម្ពន្ធទន្លេកម្ពុជា, ប្រទេសកម្ពុជា និងជានាយកប្រតិបត្តិនៃសមាគមអភិរក្សវប្បធម៌និងបរិស្ថាន, ប្រទេសកម្ពុជា
អ៊ីម៉េល៖ tep@cepa-cambodia.org, Tel: +855 12 895 624

**លោក នីវ៉ាត់ រ៉ យកែវ** មកពីអង្គការអភិរក្ស ឈៀងខុង, ឈៀងម៉ៃ, ប្រទេសថៃ
អ៊ីម៉េល៖ mekonglover@hotmail.com, Tel: +66 89 955 7890

# ទំនប់សាយាប៊ូរី ត្រូវបានដកចេញពីរបៀបវារៈក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ

## សេចក្ដីសម្រេចនេះមិនមែនជាដំណោះស្រាយល្អសម្រាប់កិច្ចសហប្រតិបត្តិការពាក់ព័ន្ធទន្លេមេគង្គនាពេលអនាគតទេ

**បាងកក, ប្រទេសថៃ៖** គណៈគ្រប់គ្រងទន្លេមេគង្គបានដករបៀបវារៈយ៉ាងចម្រូងចម្រាសនៃទំនប់សាយាប៊ូរីចេញពីកិច្ចប្រជុំក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គប្រចាំឆ្នាំនៅសប្ដាហ៍នេះ។ លោកស្រី និវ៉ាត់ រ៉ យកែវមកពីអង្គការអភិរក្សទន្លេឈៀងខុងបានមានប្រសាសន៍ថា “ការខកខានមិនបានលើកមកដោះស្រាយរបៀបវារៈទំនប់សាយាប៊ូរី នៅឯកិច្ចប្រជុំក្រុមប្រឹក្សាទន្លេមេគង្គនេះ គឺគណៈកម្មការទន្លេមេគង្គកំពុងគេចពីការទទួលខុសត្រូវរបស់ខ្លួន និងការនៅស្ងៀម

មិនអាចដោះស្រាយបញ្ហាដែលបង្កឡើងដោយការសាងសង់ទំនប់សាយាប៊ូរីដែលប្រកប ដោយការបំផ្លិចបំផ្លាញ និងទំនប់ផ្សេងៗទៀតនៅពេលអនាគត នៅតាមដងទន្លេមេគង្គអស់ បញ្ហាឡើយ។

កាលពីខែវិច្ឆិកាឆ្នាំ២០១២ រដ្ឋាភិបាលឡាវ បានធ្វើពិធីបើកការដ្ឋានផ្លូវការសាងសង់ទំនប់ សាយាប៊ូរី នេះទោះបីជាមានការព្រួយបារម្ភពាក់ព័ន្ធនឹងគម្រោងនេះយ៉ាងខ្លាំងក៏ដោយ។ ប្រទេសជាសមាជិកនៃគណៈកម្មការទន្លេមេគង្គមិនអាចឈានដល់ការព្រមព្រៀងនៅមុន ដំណើរការពិគ្រោះយោបល់បានឡើយ។ ប្រទេសឡាវមិនអើពើនឹងសំណើផ្លូវការរបស់ រដ្ឋាភិបាលកម្ពុជានិងរដ្ឋាភិបាលវៀតណាមដែលសុំឲ្យមានការវាយតម្លៃអំពីផលប៉ះពាល់ឆ្លង ដែនពាក់ព័ន្ធគម្រោងនេះ ព្រមទាំងការឲ្យយោបល់ពីសំណាក់លេខាធិការដ្ឋាននៃគណៈ កម្មការទន្លេមេគង្គឲ្យពន្យារពេលសាងសង់ទំនប់នេះរហូតដល់មានការសិក្សាហ្មត់ចត់ជាមុន សិន។ អត្ថបទចុះផ្សាយក្នុងសារព័ត៌មាន ខេមបូឌា ដេលី កាលពីសប្តាហ៍មុន រដ្ឋមន្ត្រីក្រសួង បរិស្ថានកម្ពុជាបានបញ្ជាក់ឡើងវិញអំពីជំហររបស់កម្ពុជា ដោយលើកឡើងពីប្រសាសន៍របស់ ”លោក នាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានថ្លែងថា ត្រូវតែធ្វើការសិក្សាវាយតម្លៃអំពីផលប៉ះ ពាល់បរិស្ថានជាមុនសិន ដើម្បីពិនិត្យមើលថា តើវាប៉ះពាល់ដល់យើងទាំងអស់គ្នាក្នុងកម្រិត ណា ហើយយើងទាំងអស់គ្នាបានស្នើឲ្យប្រទេសឡាវគោរពសំណើសុំពន្យារពេលនេះ”។ ប្រទេសម្ចាស់ជំនួយអន្តរជាតិក៏បានលើកឡើងពីកង្វល់នេះដែរ។ កាលពីពេលថ្មីៗនេះ កាលពី ខែវិច្ឆិកា រដ្ឋាភិបាលអាមេរិកបានប្រកាសថា ខ្លួនបារម្ភថា ការសាងសង់ទំនប់នេះ កំពុងតែបន្ត មុនពេលធ្វើការសិក្សាអំពីផលប៉ះពាល់ជាមុន”។ លោកស្រី ភៀនផន ឌីតេស មកពីអង្គការ ទន្លេអន្តរជាតិបានមានប្រសាសន៍ថា “រយៈពេលជាពីរឆ្នាំនេះ សំណើសាងសង់ទំនប់សាយាប៊ូរី បានបែងចែកការគ្រប់គ្រងក្នុងតំបន់ហើយបានក្លាយជាវិវាទមួយក្នុងចំណោមវិវាទធំៗពាក់ព័ន្ធ ដែនទឹក ឆ្លងដែនក្នុងពិភពលោក។ ខណៈដែលប្រទេសឡាវបានបដិសេធហើយបដិសេធ ទៀត មិនព្រមសហការជាមួយប្រទេសជិតខាងខ្លួន នោះគឺគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលទេដែលថា បញ្ហានេះត្រូវដកចេញពីរបៀបវារៈនៃកិច្ចប្រជុំនោះ។ ប្រទេសឡាវ បានរំលោភកិច្ចព្រមព្រៀង របស់គណៈកម្មការទន្លេមេគង្គ ហើយបានធ្វើការអះអាងមិនពិតថា គម្រោងទំនប់នេះ មាននិរន្តរភាពបរិស្ថានហើយមិនអើពើនឹងកិច្ចព្រមព្រៀងទូទៅក្នុងចំណោមក្រុមអ្នកជំនាញ ជលផលថា សំណើវិធានការកាត់បន្ថយផលប៉ះពាល់ធនធានជលផលទំនងជា មិនមានប្រសិទ្ធភាពទេ”។

លោក ឈិត សំអាត នាយកប្រតិបត្តិនៃវេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជាបានមាន ប្រសាសន៍ថា “គណៈគ្រប់គ្រងប្រចាំតំបន់មានអំណាចទប់ស្កាត់សោកនាដកម្មរួម ដែលទំនង

កើតឡើង ប្រសិនបើ ទំនប់សាយាប៊ូរី និងទំនប់ដទៃទៀតនៅតាមទន្លេមេគង្គនៅតែដំណើរការទៅមុខនោះ។ ប៉ុន្តែប្រសិនបើ ដូច្នេះមែន វាអាស្រ័យលើគណៈគ្រប់គ្រងទន្លេមេគង្គចាត់វិធានការជាបន្ទាន់ដើម្បីទាមទារឲ្យផ្អាកការសាងសង់ទំនប់សាយាប៊ូរីនិងគម្រោងដទៃទៀតរហូតទាល់តែមានការសិក្សាបន្ថែម និងមានការពិគ្រោះយោបល់ជាសាធារណៈសិន។ យើងខ្ញុំសូមអំពាវនាវទៅរដ្ឋាភិបាលក្នុងតំបន់ និងប្រទេសម្ចាស់ជំនួយធ្វើឲ្យប្រាកដ ឲ្យមានការពិនិត្យឡើងវិញលើ ដំណើរការសាងសង់ ជាមុនសិន មុនពេលឲ្យគម្រោងដទៃទៀតដំណើរការទៅមុខ ដើម្បីទប់ស្កាត់គម្រោងដទៃទៀតកុំឲ្យដើរតាមលំអានដែលមានបញ្ហាដូចទំនប់សាយាប៊ូរីនេះ”។

រយៈពេលជាងបួនឆ្នាំនេះ សង្គមស៊ីវិលអ្នកសិក្សា អ្នកវិទ្យាសាស្ត្រម្ចាស់ជំនួយ និងប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ បានលើកឡើងអំពីកង្វល់ជុំវិញការគំរាមកំហែងដែលទំនប់សាយាប៊ូរី និងទំនប់ផ្សេងៗទៀតនៅតាមទន្លេមេគង្គ បានបង្កផលប៉ះពាល់ផ្នែកសន្តិសុខស្បៀងលើប្រជាជនរាប់លាននាក់និងលើប្រព័ន្ធអេកូឡូស៊ីនៃទន្លេមេគង្គ។

លោកស្រី ឡាំ ធីធុយស៊្វ មកពីបណ្តាញទន្លេវៀតណាម និងមជ្ឈមណ្ឌលស្រាវជ្រាវផ្នែកសង្គម និងអភិវឌ្ឍន៍បានមានប្រសាសន៍ថា “គេមិនទាន់ដឹងពីវិសាលភាពនិងភាពធ្ងន់ធ្ងរនៃផលប៉ះពាល់ដែលទំនប់សាយាប៊ូរី មានមកលើជីវភាពរស់នៅនិងសន្តិសុខស្បៀងរបស់ប្រជាជនដែលរស់នៅតាមដងទន្លេមេគង្គនៅឡើយទេ។ ដោយសារតែទន្លេ មានផលប្រយោជន៍រួមដូច្នេះអនាគតរបស់យើង អាស្រ័យលើរដ្ឋាភិបាលក្នុងតំបន់សហការនិងដោះស្រាយបញ្ហាពាក់ព័ន្ធនឹងទំនប់សាយាប៊ូរីនេះឲ្យបានឆាប់”។

អំឡុងការចុះទៅពិនិត្យមើលទន្លេមេគង្គផ្ទាល់កាលពីសប្តាហ៍មុន អង្គការទន្លេអន្តរជាតិបានរកឃើញថា សំណើសាងសង់ទំនប់ដទៃទៀត នៅតាមដងទន្លេមេគង្គក្នុងប្រទេសឡាវកំពុងដំណើរការទៅមុខ។

នៅឯការដ្ឋានសាងសង់ទំនប់បាក់បេងដែលមិនទាន់ឈានដល់ដំណើរការពិគ្រោះយោបល់ជាមុនរបស់គណៈកម្មការទន្លេមេគង្គនោះ អ្នកភូមិបានប្រាប់អង្គការទន្លេអន្តរជាតិថា ការអនុវត្តគម្រោងនេះរំពឹងថានឹងចាប់ផ្តើមក្នុងអំឡុងពីរខែទៅ២ខែក្រោយនេះ ដោយចាប់ផ្តើមពីការសាងសង់ផ្លូវចេញចូលទៅកាន់ទំនប់នេះ។ អ្នកភូមិក៏បានលើកឡើងដែរថា ថ្មីៗនេះក្រុមហ៊ុនចិន បានបញ្ចប់ការសិក្សាសម្រាប់ទំនប់ប៉ាក់ឡាយ និងទំនប់សាណាខាមនេះហើយ។

កាលពីខែកញ្ញាកន្លងមក អង្គការទន្លេអន្តរជាតិបានរកឃើញថា ការងារមួយចំនួនបានចាប់ផ្តើមនៅការដ្ឋានទំនប់ ដុន សាហុងហើយជាទន្លេបែកជាពីរដែលជាផ្លូវសម្រាប់ត្រីផ្លាស់ទី។

កិច្ចប្រជុំគណៈកម្មការទន្លេមេគង្គលើកទី១៩ នឹងធ្វើឡើងនៅថ្ងៃទី១៦ដល់ទី១៧ខែមករា ក្នុងខេត្តហ្លួងប្រាបាងប្រទេសឡាវ។ ប្រទេសម្ចាស់ជំនួយអន្តរជាតិដែលផ្តល់ជំនួយដល់គណៈកម្មការនេះរំពឹងថានឹងចេញផ្សាយរបាយការណ៍នៅកិច្ចប្រជុំនោះ។

**សម្រាប់ព័ត៌មានបន្ថែម៖**

- សូមកញ្ចប់ឯកសារព័ត៌មានស្តីពីទំនប់សាយាប៊ូរី និងរូបថតផ្សេងៗ, http://www.internationalrivers.org/resources/media-kit-on-the-xayaburi-dam-3412, http://www.flickr.com/photos/internationalrivers/collections/72157631938762090/